# រឿងដំណើរផ្សងព្រេង របស់មីមី នៅអាណាចក្ររាត្រីអន្ទិកា

## MEYMEY AND HER ADVENTURE AT TWILIGHT KINGDOM



អ៊ុំ សិទ្ធិសកល
ឱម រិយា

# ដំណើរផ្សងព្រេងរបស់ម៉ីម៉ីនៅអាណាចក្ររាត្រីអន្ធិកា
# MEYMEY AND HER ADVENTURE IN THE TWILIGHT KINGDOM


**Written by** Oum Sithsakal
**Artwork by** Om Virya

**Co-Editors** Sai Yee Tip,
Prak Monirath,
Uoeung Bonsovathary

**Art Editor** San Somanear

**Reviewed by** Khmer Youth Association (KYA),
Love is Diversity



Publisher Khmer Youth Association (KYA)
No. 32D, St. 562, Phnom Penh12151, Cambodia



Copyright © 2024 by Khmer Youth Association (KYA)

All rights reserved.
Without limiting the rights under the copyright reserved above, no part of this publication may be reproduced, stored in or introduced into a retrieval system, or transmitted, in any form, or by any means (electronic, mechanical, photocopying, recording, or otherwise), without the prior written permission of the copyright owner.


Published in Phnom Penh, Cambodia.

A catalog record for this book is available from
the National Library of Cambodia
ISBN: 978-9924-9966-1-3

Disclaimer: This storybook is made possible by the generous support of the American people through the United States Agency for International Development (USAID)-funded Civil Society Support (CSS) Activity implemented by Family Health International (FHI360). The contents are the responsibility of Khmer Youth Association and do not necessarily reflect the views of USAID or the United States Government.

# រឿង

# ដំណើរផ្សងព្រេងរបស់ម៉ីម៉ីនៅអាណាចក្ររាត្រីអន្ធិកា

# MEYMEY AND HER ADVENTURE IN THE TWILIGHT KINGDOM




នៅវិទ្យាល័យមួយក្នុងខេត្ត...


អេ មុីមុី! យ៉ាងម៉េចហើយ ប្រឡងថ្ងៃនេះ?
មិនដឹងយ៉ាងម៉េច យ៉ាងណាទេ។ សង្ស័យ តែធ្លាក់ទេលីណា
មិនអីទេ បើធ្លាក់យ៉ាងច្រើន ជួយបោសជូតថ្នាក់មួយខែទៅ អ្នកគ្រូគាត់ឱ្យជាប់ហើយ។ ចាំខ្ញុំ ជួយបោស ហេស ហេ
អីចឹងក៏បានឱ្យតែខ្ញុំ បាននៅជាមួយ លីណាឯងតែពីរនាក់
(លីណា និងមុីមុីសើច ហើយក៏លេងចាក់ក្រឡេកជាមួយគ្នា)


ខ្លាចគេឃើញ! ហ៊ុម!
និយាយអីចឹងល្ងាចណាស់ហើយ
យើងគួរតែប្រញាប់ទៅផ្ទះខ្លាច
ប៉ាម៉ាក់ចាំផ្លូវពិសាបាយ


ម៉ីម៉ីឯងប្រាកដក្នុងចិត្ត ឬអត់ថាចង់ប្រាប់លោកពូអ្នកមីងពីទំនាក់ទំនងរបស់យើងពីរនាក់? ខ្ញុំខ្លាចតែគាត់មិនយល់ស្របនោះទេ។
ជិតប្រឡងបាក់ឌុបហើយ ខ្ញុំចង់ទៅរៀនបន្តជាមួយលីណាឯងពេលចូលសាកលវិទ្យាល័យ បើមិនប្រាប់ពួកគាត់ទៀតមិនកើតទេ គាត់ច្បាស់ជាបង្ខំខ្ញុំឱ្យជួយលក់ដូរគាត់មិនខានទេ។
(លីណា និងម៉ីម៉ីដើរទៅផ្ទះម៉ីម៉ី...)


(ប្រវត្តិសង្ខេបពីមិត្តភាពរបស់ម៉ីម៉ី និងលីណា)
ម៉ីម៉ី និងលីណាជាមិត្តល្អនឹងគ្នាតាំងពីថ្នាក់ទី៣
ហើយបានដើរលេង ជាមួយគ្នាគ្រប់ពេល។
ឪពុកម្ដាយលីណាមានចិត្តទូលាយ តែងតែឱ្យលីណាមកហូបបាយ ឬគេងនៅផ្ទះម៉ីម៉ីជារឿយៗ។
គ្រួសារទាំងពីរជាអ្នកភូមិតែមួយ ហើយធ្លាប់ជប់លៀងជាមួយគ្នា ច្រើនដងដែរ។
ទោះបីជាយ៉ាងណាក្ដីគ្រួសាររបស់ ម៉ីម៉ីនៅមិនទាន់ដឹងពីទំនាក់ទំនងពិត របស់ពួកគេពីរនាក់នៅឡើយទេ។


*នៅផ្ទះម៉ីម៉ី...
ក្រោយបាយល្ងាចរួច
លីណាក៏ធ្វើពុតជាទៅនិយាយទូរស័ព្ទជាមួយម្ដាយនាងនៅខាងក្រៅផ្ទះ ដើម្បីឱ្យម៉ីម៉ីមានឱកាសនិយាយជាមួយឪពុកម្ដាយនាង។


និយាយអីចឹង លោកប៉ាអ្នកម៉ាក់ កូនមានរឿងមួយចង់ប្រាប់ប៉ាម៉ាក់។
មានរឿងអីកូន?
ពេលរៀនវិទ្យាល័យចប់ កូនចង់ទៅរៀនតនៅទីក្រុង។
ទៀតហើយ ប៉ានិយាយប្រាប់មិនចេះស្តាប់សោះ។ ហើយរៀននៅស្រុកជិតផ្ទះទៅវាថី?
ឯងទៅបាត់បានអ្នកណានៅជួយរកស៊ីប៉ាម៉ាក់?


គឺថា...គឺថា...ខ្ញុំ និងលីណាគឺ... គឺ..
ខ្ញុំមិនចង់នៅទីនេះទៀតទេ
មកពីខ្ញុំស្រលាញ់លីណា ហើយចង់ទៅរៀនជាមួយលីណា
ថាម៉េច?
ពុទ្ធោ កូនខ្ញុំ...
ឃើញទេ ថាកុំបណ្តោយវាច្រើនពេកឥឡូវវាបែកឆ្វេងទៅស្រលាញ់ស្រី
ប៉ាម៉ាក់ស្តាប់ខ្ញុំសិន


មិនបាច់ និយាយច្រើនទេ ខែក្រោយឈប់ រៀនទៅ ហើយ ទៅជួយម៉ាក់ឯង លក់ដូរទៅ
ប៉ា ខ្ញុំមិនឈប់ទេ ខ្ញុំចង់ចេញពីផ្ទះនេះឱ្យ កាន់តែលឿនកាន់តែល្អ។
បានហើយ ឈប់ មាត់! អីចឹងតើបាន រកស៊ីមិនឡើងសោះ មកពីយើងសាង បាបពីជាតិមុនបាន មានកូនដូចជាឯង ហ្នឹង។
ហេតុអីប៉ាមានគំនិត ចាស់គំរិលអីចឹង? មិនមែនដោយសារតែ រឿងនេះដែលធ្វើឱ្យ យើងរកស៊ីមិនឡើង នោះទេ។
រឿងខ្លះទោះបីខំយ៉ាងណាក៏រកស៊ីមិនឡើងដែរ។
ថាម៉េច? យី! កូននេះ និយាយគ្មានគោរព ចាស់ទុំអីសោះ។
ប៉ារបស់មុីមុីងើបឡើងយ៉ាងលឿន ហើយ លើកដៃបម្រុងនឹងដាល់មុីមុី តែ...


តែម៉ាក់របស់នាងរត់ទៅឈរពាំង ទាំងទឹកភ្នែក។
ប៉ាមុីមុីបោះសំដីទៅមុីមុីថា...
ខំចិញ្ចឹមតាំងពីតូចមក ហេតុអីបានដឹងក្ដីទៅជាអីចឹង? ឆាប់ចេញពីផ្ទះនេះភ្លាមកុំ យើងឃើញមុខទៀត។


លីណាកំពុងអង្គុយលេងលើទោងយោលទៅវិញទៅមកក្នុង
សួនច្បារខាងក្រៅផ្ទះ ស្រាប់តែឃើញមុីមុីរត់យ៉ាងលឿនចេញពីផ្ទះ។
មុីមុី! ឈប់សិន មានរឿងអី កើតឡើង ហ្នឹង?
ស្ដាប់ខ្ញុំសិន! កុំរត់លឿនពេក! ចាំខ្ញុំផង!




មន្ទីរពេទ្យ




*វិញ្ញាណមនុស្ស និងសត្វតែងតែមករស់នៅទីនេះសិន
មុននឹងទៅចាប់កំណើតជាថ្មី*


យ៉ាងម៉េចហើយ មុីមុី? តើកូនឃ្លាន ដែរ ឬទេ?
មួយរំពេចនោះ មុីមុីភ្ញាក់ដឹងខ្លួននៅក្នុងពិភពមួយដ៏ស្រស់ស្អាត។ នាងក្រឡេក មើលជុំវិញខ្លួនរបស់នាងឃើញទេពធីតាមួយអង្គកំពុងញញឹមដាក់នាង។
ចាំម៉ាក់យកនំមក ឱ្យកូនញុាំ។
តើខ្ញុំនៅទីណា ហ្នឹង?
កូនកំពុងនៅ អាណាចក្ររាត្រីអន្ធិកា ណាកូន
អាណាចក្ររាត្រីអន្ធិកា ជាអ្វីទៅ? ហើយអ្នក គឺជាអ្វីដែរ?
អាណាចក្ររាត្រីអន្ធិកា ជាអាណាចក្រមួយ ដែលស្ថិតនៅចន្លោះពិភពរបស់មនុស្សលោក និងឋានសួគ៌។ ម៉ាក់ជាទេពអប្សរនៅទីនេះ ដែលមានតួនាទីការពារច្រកចេញចូលរវាង ពិភពមនុស្ស និងអាណាចក្រនេះ កុំឱ្យមនុស្ស និងវិញ្ញាណចេញចូលផ្ដេសផ្ដាស។
កូនស្គម យ៉ាងនេះ ញុាំឱ្យ ច្រើនទៅកូន
១៥


អាណាចក្ររាត្រីអន្ធិកាពិតជាគួរឱ្យចង់នៅណាស់។ គ្រប់វិញ្ញាណមនុស្ស និងសត្វដែលនៅទីនោះហាក់ដូចជាស្វាគមន៍ និងចូលចិត្តម៉ុម៉ុណាស់។
?
ទេពអប្សរក៏ចូលចិត្តនាងដែរ ព្រមទាំងផ្ដល់ឱ្យនាងនូវអាហារ និងភេសជ្ជៈឆ្ងាញ់ៗទៀតផង។


ទេពអប្សរជាទីគោរព ខ្ញុំពិតជាដឹងគុណទេពអប្សរណាស់ដែលបានមើលថែខ្ញុំនៅប៉ុន្មានថ្ងៃនេះ ក៏ប៉ុន្តែខ្ញុំពិតជានឹកមិត្តភក្តិ និងក្រុមគ្រួសាររបស់ខ្ញុំណាស់ តើមានវិធីអ្វីដែលអាចឱ្យខ្ញុំអាចត្រឡប់ទៅពិភពមនុស្សវិញបាន ឬទេ?



មិនអីទេកូន ម៉ាក់នឹងជប់វេទមន្តបង្ហាញឱ្យកូនឃើញពីសុខទុក្ខរបស់ពួកគាត់។
ឃើញទេមីុមីុកូន? ពួកគាត់គ្មានពេលនឹកនាកូនទេ។ យកល្អកូនគួរតែនៅជាមួយម៉ាក់ជារៀងរហូតទៅ។


ទោះជាយ៉ាងម៉េចក៏ដោយ តែខ្ញុំនៅតែចង់ជួបពួកគាត់ម្តងទៀត ដើម្បីឱ្យដឹងសខ្មៅ
ម៉ីម៉ីកូនជាធម្មតា វិញ្ញាណដូចជាកូនមិនអាចចាកចេញតាមចិត្តបានទេ បើសិនជាធ្វើអីចឹងវានឹងនាំមកក្តីអន្តរាយដល់អាណាចក្រព្រមទាំងពិភពមនុស្សផងដែរ ម៉ាក់នឹងរៀបចំការប្រកួតមួយ។
ដើម្បីសាកល្បងថាកូនអាចវិលទៅពិភពមនុស្សបាន ឬទេ។
ការប្រកួត?


« តើទេពធីតាហៅពួកយើងមកធ្វើអ្វី? »
សួស្តីកូនៗទាំងអស់គ្នា នេះជាមុីមុី។ នាងចង់វិលទៅ ពិភពមនុស្សដើម្បីទៅជួបមនុស្ស ដែលនាងស្រលាញ់ឈ្មោះលីណា ព្រមទាំងគ្រួសាររបស់នាង។ ម៉ាក់ នឹងរៀបចំការប្រកួតជាបន្តបន្ទាប់
សូមព្យាយាម ឱ្យអស់ពី សមត្ថភាព ណាកូនៗ
«បាទ/ចាំ»

***ការប្រកួតទី១ នោះគឺការលេងបោះអង្គញ់៖**
ល្បែងបោះអង្គញ់ត្រូវបានដាក់ឈ្មោះតាមផ្លែអង្គញ់។ ល្បែងបោះអង្គញ់អាចរាប់ចូលក្នុងប្រភេទកីឡា ដែលហាត់ដៃឱ្យត្រង់ ហាត់ភ្នែក និងរឹកហាត់ស្មារតីឱ្យនឹងនរ។ ដើមឡើយ ប្រជាពលរដ្ឋកម្ពុជាគ្រប់វ័យចូលចិត្តលេងល្បែងបោះអង្គញ់យ៉ាងខ្លាំងក្នុងរដូវចូលឆ្នាំខ្មែរ។






រីឯមុីមុីមានការគិតឈ្លាសវៃនាងបាន
បោះអង្គញ់ដោយមានការតាំងចិត្តខ្ពស់តម្រង់
ទិសដៅឱ្យចំរហូតធ្វើឱ្យនាងបោះចំគោលដៅ
ល្អតាមការរំពឹងទុក។
ម្យ៉ាងទៀត ពេលដាំអង្គញ់ មុីមុី
បានចាក់ទឹកលើខ្សាច់ដើម្បីឱ្យ
ខ្សាច់សើម ងាយស្រួលដាំមិន
ងាយដួលជាងខ្សាច់ស្ងួត។


យេ! ខ្ញុំឈ្នះហើយ។
ដូច្នេះ ខ្ញុំអាចវិលទៅរកពិភពមនុស្សវិញបានហើយ ត្រូវទេទេពធីតា?
អបអរសាទរកូនស្រី ម៉ាក់ពិតជាសប្បាយចិត្តណាស់ កូនពិតជាឆ្លាតមែន ក៏ប៉ុន្តែកូនបានចាក់ទឹកទៅលើខ្សាច់ កូនធ្វើអីចឹងលេងខូចគេហើយម៉ាក់មិនអាចទទួលយកលទ្ធផលនេះបានទេ?
អីចឹងធ្វើម៉េចខ្ញុំអាចទៅវិញកើតទៅ?
ឥឡូវបែបនេះ ម៉ាក់នឹងរៀបចំការប្រកួតម្តងទៀតជាវិញ្ញាសារផ្សេង។


ការប្រកួតទី ២ គឺជាការប្រកួតឡើងសសរខ្លាញ់៖ ថ្វីត្បិតតែមាឌល្អិតតូច ហើយមិនសូវមានកម្លាំងប្រឹងពិតមែន តែនាងជាក្មេងស្រីឆ្លាតម្នាក់។
មុីមុីដោះស្រោមជើងរបស់នាង រួចយកស្រោមជើងមួយគូនោះមកចងដៃរបស់នាងឱ្យជាប់គ្នា
មកចងដៃរបស់នាងឱ្យជាប់គ្នា ដើម្បីងាយស្រួលឱបឡើងសសរ
កុំឱ្យរអិលដូចប្រើដៃទទេរ។
យេ! ទីបំផុត ខ្ញុំឡើងដល់ហើយ
បន្ទាប់មកនាងក៏ចាក់ទឹកលើសម្លៀកបំពាក់នាងឱ្យសើម ដើម្បីកុំឱ្យរអិលខ្លាញ់ពេលឱបឡើងសសរ។ ចុងក្រោយនាងបានឡើងបង្គោលម្តងមួយៗរាងដូចដង្កូវនាងរហូតដល់កំពូល រីឯក្មេងៗដទៃទៀតមិនអាចឡើងរួច។

ភ្លាមៗនោះម៉ីម៉ីសង្កេតឃើញថា សោភណ័ភាពរបស់អាណាចក្ររឹតតែដុនដាប
ជាងពីមុនទៅទៀត រីឯទេពអប្សរវិញមើលទៅហាក់បីដូចជាខឹងសម្បារយ៉ាងខ្លាំង




ម៉ីម៉ីមានអារម្មណ៍ថាភ័យខ្លាច ហើយដឹងថាទេពអប្សរមិនមានបំណងល្អចង់
ដោះលែងខ្លួននោះទេ ក៏ប៉ុន្តែម៉ីម៉ីព្យាយាមលាក់បាំងភាពភ័យខ្លាចរបស់ខ្លួន
ហើយសុំទេពអប្សរភ្នាល់គ្នាជាលើកចុងក្រោយថា...


ឥឡូវ បែបនេះទៅ
កូនសុំភ្នាល់គ្នា ជាមួយនឹងទេពអប្សរ ជាលើកចុងក្រោយ។
ហ៊ឹយ... និយាយ លក្ខខណ្ឌមក
កូននឹងវិលត្រលប់ ទៅអតីតកាលដើម្បី និយាយជាមួយប៉ាម៉ាក់ កូនម្ដងទៀត ដើម្បី បញ្ចុះបញ្ចូលពួកគាត់ឱ្យ ទទួលស្គាល់ទំនាក់ទំនង របស់កូន និងលីណា។
បើពួកគាត់យល់ព្រម ខ្ញុំនឹងអាចវិលទៅពិភព មនុស្សលោកវិញបាន។
ចុះបើប៉ាម៉ាក់មុីមុី មិនព្រមវិញ?
នោះខ្ញុំនឹងរស់នៅ អាណាចក្ររាត្រីអន្ធិកា ជាមួយម៉ាក់ជារៀង រហូត។


ទេពអប្សរមានអារម្មណ៍សង្ស័យមិនជឿពាក្យម៉ីម៉ីនិយាយនោះឡើយ។
នៅពេលទ្បានរៀបនឹងបុកពួកខ្ញុំទាំងពីរ ខ្ញុំនឹងមិនរុញលីណាចេញពីទ្បានទេ លីណានឹងមកនៅអាណាចក្ររាត្រីអន្ទិកាជាមួយនឹងខ្ញុំ តែខ្ញុំមានលក្ខខណ្ឌមួយគឺខ្ញុំសុំទៅសួរសុខទុក្ខលីណា និងប៉ាម៉ាក់ខ្ញុំជាលើកចុងក្រោយ។
បានម៉ាត់ណា ម៉ាត់ហ្នឹង។
ទេពអប្សរព្រមហើយក៏រំជួលចិត្តលោភលន់ជឿថាម៉ីម៉ីនឹងអាត្មានិយមមិនជួយលីណាពិតមែន។ ទេពអប្សរក៏ជប់វេទមន្តបញ្ជូនម៉ីម៉ីទៅពិភពមនុស្ស ដើម្បីឱ្យនាងបានសួរសុខទុក្ខលីណា និងប៉ាម៉ាក់របស់នាង។



មុីមុីឃើញលីណា និងប៉ាម៉ាក់របស់នាងអង្គុយក្បែរគ្រែនាង ហើយបន់ស្រន់ឱ្យនាងត្រឡប់មកវិញ។ នាងដឹងថាការបង្ហាញរបស់ទេពអប្សរពីមុន គឺក្លែងក្លាយទាំងអស់។ នាងមានអារម្មណ៍រំជួលចិត្តយ៉ាងខ្លាំង បន្ទាប់ពីបានឃើញពួកគាត់ ជាពិសេសឪពុកម្ដាយរបស់នាងយំស្រែកយ៉ាងខ្លាំង និងបន់ស្រន់ដើម្បីឱ្យនាងត្រឡប់មកវិញ។




ទោះបីជាម៉ីម៉ីប្រឹងហៅប៉ុណ្ណាក៏ពួកគាត់មិនឮដែរ ព្រោះមនុស្សមិនអាចស្ដាប់ឮព្រលឹងនិយាយនោះឡើយ។
ប៉ុណ្ណឹងបានហើយ!
ម៉ីម៉ីត្រលប់មកអតីតកាលវិញ ហើយឃើញលីណារៀបចេញទៅនិយាយទូរស័ព្ទនៅខាងក្រៅផ្ទះ


លោកប៉ា អ្នកម៉ាក់ កូនមានរឿងមួយ ចង់ប្រាប់ប៉ាម៉ាក់ឱ្យដឹង ព្រោះប៉ាម៉ាក់ ទាំងពីរជាមនុស្សសំខាន់បំផុតក្នុងជីវិត របស់កូន។ កូនព្យាយាមលាក់រឿងនេះ ជាយូរណាស់មកហើយ តែកូនមិន អាចលាក់វាបានទៀតទេ កូនសម្រេច ចិត្តហ៊ានប្រាប់ប៉ាម៉ាក់ពីរឿងនេះ
ព្រោះកូនស្រលាញ់ប៉ាម៉ាក់ទាំងពីរខ្លាំង ណាស់ ពេលលោកទាំងពីរឮហើយ កូនសុំចិត្តលោកប៉ាអ្នកម៉ាក់កុំទាន់អាល ខឹងអី ស្ដាប់កូនពន្យល់ឱ្យចប់សិន។
ប៉ាម៉ាក់មីមីមើលមុខគ្នាយ៉ាងងឿងឆ្ងល់
មានរឿង អីកូន?
ពេលឮហើយប៉ាម៉ាក់មីមីចាប់ផ្ដើមប្រែទឹកមុខ រីឯថ្ងាសមីមីក៏បែកញើសជោក
និយាយទៅគឺបែបនេះកូន និង លីណាជាមិត្តភក្តិយូរណាស់មក ហើយ ក៏ប៉ុន្តែ... នែ ក្តីស្រលាញ់ របស់កូន និងលីណាគឺស្និទ្ធស្នាល ជាងមិត្តភក្តិទៅទៀត។


ទោះបីពីរនាក់ខ្ញុំជាក្មេងស្រីក៏ដោយ ពេល កូននៅជាមួយលីណា កូនមានអារម្មណ៍ ថាសប្បាយចិត្ត និងកក់ក្ដៅ
ប្រៀបបីដូចជាក្ដីស្រលាញ់របស់លោកប៉ា ចំពោះអ្នកម៉ាក់ដែរ កូនមិនដែលមានអារម្មណ៍បែបនេះ ជាមួយនរណាម្នាក់ឡើយ ហើយក៏មិនយល់ថាអ្វីជាស្នេហាដែរ រហូតដល់កូនស្គាល់លីណា។ កូនបានព្យាយាមទប់ខ្លួនឯងណាស់ ដែរ តែនេះជានិស្ស័យធម្មជាតិរបស់កូន។ កូនមិនអាចបង្ខំខ្លួនឯង ឱ្យបដិសេធសេចក្ដីស្រលាញ់នេះទៀតឡើយ។
ពេលស្ដាប់ចប់ហើយមីមីសង្កេតឃើញថាប៉ារបស់មុីមុីហាក់បីដូចជាមាន អារម្មណ៍ថារំភើបក្ដុកក្ដួល ស្រាប់តែរំពេចនោះទេពអប្សរក៏លេចមុខឡើង ពីក្រោយប៉ាម៉ាក់មុីមុីហើយមើលមុខនាងត្លឹះៗ។ មុីមុីស្រឡាំងកាំងតែព្យាយាម រក្សាអារម្មណ៍របស់នាងឱ្យនឹងនរ។
កូនចង់ទៅរៀនជាមួយនាង នៅក្រុង កូនមិនចង់នៅខេត្ត ទៀតទេ... សូមលោកប៉ាអ្នក ម៉ាក់កុំខឹងអី


ហ្អឹងហើយថាកុំឱ្យបណ្តោយ វាច្រើនពេក ឥលូវវាបែកឆ្វេង ទៅស្រលាញ់ស្រី។
ពុទ្ធោ...កូនខ្ញុំ
លោកប៉ាអ្នកម៉ាក់ ពេលទៅរៀននៅភ្នំពេញជាមួយលីណា កូននឹងព្យាយាមឱ្យអស់ពីសមត្ថភាពដើម្បីរកការងារល្អ មានប្រាក់ខែច្រើន។
កូននឹងមិនធ្វើឱ្យលោកទាំងពីរខកចិត្តនឹងអនាគតរបស់កូនឡើយ សូមកុំបារម្ភពីកូន។ អ្វីដែលកូនត្រូវការពីលោកទាំងពីរ គឺការទទួលស្គាល់ និងសេចក្តីស្រលាញ់របស់ប៉ាម៉ាក់តែប៉ុណ្ណោះ។
ពេលឮហើយម៉ាក់របស់ម៉ីម៉ីងាកមើលប៉ារបស់ម៉ីម៉ី រីឯប៉ាម៉ីម៉ីមើលទៅទន់ចិត្ត តែមិននិយាយអ្វីទាំងអស់ រីឯទេពធីតាមើលទៅហាក់បីដូចជាខឹងយ៉ាងខ្លាំង។


ទោះបីជាម៉ីម៉ីប្រឹងនិយាយយ៉ាងណា ក៏លទ្ធផលនៅតែដដែល ប៉ារបស់នាងមិន
អាចឈប់គិតពីទំនៀមទម្លាប់ពីបុរាណដែលថា មនុស្សប្រុស និងមនុស្សស្រី
ទើបស្រលាញ់គ្នាបាន។
ប៉ាមិនអាចទទួលយករឿងនេះ បានទេ វាហួសហេតុពេកហើយ។ ទេ! មិនកើតទេ។
ទៅថ្ងៃខាងមុខ កូនមិនអាចរស់ ដោយគ្មានលីណាបាននោះទេ។
រំពេចនោះទេពធីតាក៏សើចយ៉ាង
ខ្លាំងៗនិងកាចសាហាវហើយក៏អូស
ម៉ីម៉ីមកអាណាចក្ររាត្រីអន្ធិការវិញ
កូនសូមលាហើយ លោកប៉ា អ្នកម៉ាក់...


ព្រោះតែមុីមុីដឹងថាខ្លួនមិនអាចផ្លាស់ប្តូរអតីតកាលបាន មុីមុីក៏សម្រេចចិត្តរត់ទៅ
ក្រៅដើម្បីឱ្យឧបទ្ទវហេតុដែលពីបានអតីតកាលកើតឡើងតាមវាសនារបស់នាង
លីណា! ឆាប់ចេញទៅ!
ទេ!!!
តែលើកនេះនៅពេលដែលមុីមុីព្យាយាមប្រានលីណាចេញ លីណាចាប់បាន
ដៃរបស់មុីមុី ហើយទាញនាងចូលមកផ្លូវដើរវិញ។ ឃើញមុីមុីមិនអី រំពេចនោះ
ទេពអប្សរក៏ប្រែទៅជាបិសាចគួរឱ្យខ្លាច។ មុីមុីនិងលីណាក៏ឱបគ្នាយ៉ាងភ័យខ្លាច


លីណា! ខ្ញុំស្រលាញ់ឯងណាស់!
បើមានជាតិក្រោយមែន ខ្ញុំប្រាថ្នា
សូមជួបនាងម្តងទៀត កុំឱ្យជួបនឹង
ការរើសអើងបែបនេះទៀតអី
ម៉ីម៉ី!
ខ្ញុំក៏ស្រលាញ់...


ទេ!!!
រំពេចនោះឡានមួយបានបុកបិសាចនោះ
បន្ទាប់មកបិសាចក៏រលាយបាត់ទៅ


ភ្លាមៗនោះ ប៉ាម៉ីម៉ីបានភ្ញាក់ពីសុបិន្ត។
សុបិន្តនៃហេតុការណ៍ទាំងអស់នោះ។
ពុទ្ធោកូន កូនខំប្រឹងយ៉ាងនេះដើម្បីឱ្យប៉ាស្រលាញ់កូន កូនដឹងខ្លួនឡើង មករកប៉ាវិញមកកូន
ទោះជាគាត់បន់ស្រន់អង្វរយ៉ាងណាក៏ម៉ីម៉ី នៅតែសន្លប់ស្តូកស្តឹងដដែល។


ប៉ាសន្យាថា មិនថាកូនក្លាយទៅជាបែបណាក៏ប៉ាទទួលស្គាល់កូនដែរ។ កូនស្រីរបស់ខ្ញុំនៅតែជាកូនស្រីរបស់ខ្ញុំ។ កូនដឹងខ្លួនឡើងមករកប៉ាវិញមកកូន។

ប៉ាស្រលាញ់កូន
លោកពូ
អ្នកមីង
មើលនោះណ៎!


កូនក៏ស្រលាញ់ម៉ាក់ប៉ាដែរ...។
កូនស្រលាញ់អ្នកទាំងអស់គ្នា


មួយអាទិត្យក្រោយមក...

មីមី និងប៉ាម៉ាក់នាងបានអញ្ជើញលីណា និងម៉ាក់នាងមកផ្ទះមីមីពិសាបាយពេលល្ងាចយ៉ាងសប្បាយអឹងកង។



មីមី និងលីណាទីបំផុតអាចកាន់ដៃគ្នានៅលើតុបាន






ស្រមោលទេពអប្សរ



ISBN: 978-9924-9966-1-3